**ធម្មទេសនារបស់លោកអភិបាលអូលីវីយេ**
**អភិបូជាអភិបូជាអាពាហ៍ពិពាហ៍នៅបឹងតាព្រហ្ម**
**ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៨**
*គ្រួសារថ្មីត្រូវធ្វើជាអំបិលនិងពន្លឺសម្រាប់សង្គម*

| |
|---|
| អត្ថបទទី១៖ សុភ ៣១,១០-១៣.១៩-២០.៣០-៣១<br>ដំណឹងល្អ៖ មថ ៥,១៣-១៦ |

បងប្អូនជាទីស្រឡាញ់!

យើងមានអំណរសប្បាយជួបជុំគ្នាក្នុងអាពាហ៍ពិពាហ៍ ជាពេលវេលាមួយសំខាន់បំផុតនៅក្នុងជីវិតរបស់កូនកម្លោះកូនក្រមុំ។ ពិសេសសម្រាប់យើងថ្ងៃនេះដោយសារ នេះជាអាពាហ៍ពិពាហ៍សម្រាប់គ្រីស្តបរិស័ទទាំងពីរនាក់ ព្រះសហគមន៍បានបង្កើតគ្រួសារថ្មីនៅក្នុងសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់។ អរព្រះគុណព្រះជាម្ចាស់ សម្រាប់វត្តមានរបស់ព្រះអង្គដែលកំពង់គង់នៅក្នុងអគ្គសញ្ញាអាពាហ៍ពិពាហ៍។ អគ្គសញ្ញាអាពាហ៍ពិពាហ៍ ពិតមែនយើងមានសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់នៅក្នុងកូនកម្លោះកូនក្រមុំ ដែលណែនាំឲ្យមានអនាគតពិសេសនៅក្នុងសុភមង្គលនិងសេចក្ដីសុខ។ អត្ថបទទីមួយដែលយើងស្ដាប់ថ្ងៃនេះ "**រីឯសម្រស់ស្អាតមិនស្ថិតស្ថេរហួតទេ មានតែស្ត្រីដែលគោរពកោតខ្លាចព្រះអម្ចាស់ប៉ុណ្ណោះដែលគួរកោតសរសើរ**"។ ប្ដីប្រពន្ធពិថ្ងៃនេះយើងស្អាតអស់កាលជានិច្ច ដោយសារប្ដីប្រពន្ធនៅក្នុងសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ ដោយសារយើងបានទទួលសេចក្ដីស្រឡាញ់របស់ព្រះអង្គសម្រាប់អស់មួយជីវិត។ ទោះបីជីវិតរបស់យើងចាស់ទៅៗ ប៉ុន្តែសេចក្ដីស្រឡាញ់នៅថ្មីដដែល ដោយសារសេចក្ដីស្រឡាញ់ដែលយើងបានទទួលពីព្រះជាម្ចាស់។

នៅក្នុងឆ្នាំនៃគ្រួសារ ជាឱកាសមួយយ៉ាងអស្ចារ្យសម្រាប់យើងជាគ្រីស្តបរិស័ទ ជាប្ដីប្រពន្ធ ឬកំពុងគិតបង្កើតគ្រួសារ ថ្ងៃនេះយើងមានគំរូមយយនៅក្នុងសេចក្ដីស្រឡាញ់។ សេចក្ដីស្រឡាញ់នេះ ត្រូវការណែនាំឲ្យបើកចិត្តគំនិតទូលំទូលាយ ដើម្បីឲ្យចេក្ដីស្រឡាញ់ដែលយើងទទួលថ្ងៃនេះ និងរបៀបដែលយើងបម្រើព្រះសហគមន៍ និងសង្គមក៏ជាការអស្ចារ្យដើម្បីជួយឲ្យសេចក្ដីស្រឡាញ់របស់យើង មានឥទ្ធិពលលើបងប្អូនឯទៀតៗ។ យើងមិនគិតអំពីខ្លួនឯង អ្វីដែលយើងកំពុងធ្វើសព្វថ្ងៃដើម្បីជួយបងប្អូនឯទៀតៗត្រូវការបន្តទៀតដើម្បីឲ្យសុភមង្គលយ៉ាងពិតប្រាកដ មិនចេញដោយសារយើងជាប្ដីប្រពន្ធដែលចេះស្រឡាញ់គ្នាទៅវិញទៅមកតែប៉ុណ្ណឹង ប៉ុន្តែសុភមង្គលដ៏ពិតប្រាកដចេញដោយសារយើងមានសមត្ថភាពដើម្បីមើលបងប្អូនឯទៀតៗ។ គ្រួសារនីមួយៗ ត្រូវទៅជាអំបិលនិងពន្លឺមួយ

ដើម្បីណែនាំឲ្យសង្គមរបស់យើងទៅជាសង្គមថ្មី។ ឆ្នាំថ្មីឲ្យយើងបង្កើតក្រុមគ្រួសារថ្មីនៅក្នុងសង្គមថ្មី ថ្ងៃនេះយើងមានគ្រួសារថ្មីមួយឲ្យយើងបន្តធ្វើជាពន្លឺនិងធ្វើជាអំបិលសម្រាប់បងប្អូនឯទៀតៗជានិច្ច។ យើងមានគ្នាតិច ដែលជាគ្រីស្តបរិស័ទក្នុងសង្គមកម្ពុជាយើងបច្ចុប្បន្ននេះ ប៉ុន្តែឲ្យយើងថែរក្សាសេចក្តីស្រឡាញ់ សេចក្តីសង្ឃឹមដែលយើងមាននៅក្នុងខ្លួន ធ្វើឲ្យជីវិតរបស់យើងទៅជាជីវិតគំរូសម្រាប់បងប្អូនឯទៀតៗ។ យើងមានតួនាទីច្រើនណាស់ដើម្បីបន្តតស៊ូ ដើម្បីស្រឡាញ់គ្នាដោយមានសេចក្តីសុខនិងសុភមង្គល ហើយចែកសេចក្តីសុខនិងសុភមង្គលនេះដល់បងប្អូនឯទៀតៗ។

ពេលយើងរៀបការយើងមានសុភមង្គល ពេលយើងចាស់ទៅមានកូនដែលមើលថែរក្សាយើង ប៉ុន្តែសុភមង្គលយើងត្រូវកសាងចាប់ពីពេលនេះតទៅ ឲ្យជីវិតរបស់យើងទៅជាជីវិតដែលចេះតស៊ូ ដើម្បីរកការងារល្អ ដើម្បីចិញ្ចឹមគ្រួសារ ដើម្បីសម្រុះសម្រួលបញ្ហាគ្រួសារ...ដើម្បីឲ្យសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់បំភ្លឺជានិច្ច។

យើងអរព្រះគុណព្រះជាម្ចាស់ សូមព្រះអង្គប្រទានពរដល់គ្រួសារថ្មីនេះចេះស្រឡាញ់គ្នាយ៉ាងពិតប្រាកដបង្កើតគ្រួសារដ៏សុខសាន្តមួយយ៉ាងពិតប្រាកដ ដោយធ្វើជាអំបិលនិងពន្លឺសម្រាប់បងប្អូនឯទៀតៗជានិច្ច។ យើងខ្ញុំសូមទូលអង្វរព្រះជាម្ចាស់ សូមព្រះវិញ្ញាណដ៏វិសុទ្ធគង់នៅជាមួយគ្រួសារថ្មីនេះ ដើម្បីឲ្យសេចក្តីស្រឡាញ់របស់ព្រះអង្គទៅជាកម្លាំងមួយយ៉ាងពិសេស ឲ្យរកឃើញសុភមង្គលយ៉ាងពិតប្រាកដនៅថ្ងៃអនាគតជានិច្ច។ អាម៉ែន៕